# អនុសញ្ញាឆ្នាំ២០០១ របស់អង្គការយូណេស្កូស្ដីអំពីការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

## ហេតុអ្វី?

បេតិកភណ្ឌលិចក្នុងទឹកទទួលបានការការពារតិចជាងសម្បត្តិវប្បធម៌នៅលើដី ដោយហេតុថាសម្បត្តិវប្បធម៌នៅលើដីបានក្លាយជាកម្មវត្ថុនៃការស្រាវជ្រាវអស់រយៈពេលយូរជាង។ ដោយសារបេតិកភណ្ឌវប្បធម៌ក្រោមទឹក ទើបតែត្រូវបានគេចុះទៅមើលដល់ទីកន្លែងកាលពីពេលថ្មីៗកន្លងមកនេះ តាមពិតតាំងពី ឆ្នាំ១៩៤០ប៉ុណ្ណោះទេ ទើបលិខិតតូបករណ៍ច្បាប់គ្រប់ជ្រុងជ្រោយសម្រាប់កិច្ចសហប្រតិបត្តិការរវាងបណ្ដារដ្ឋនានា នៅខ្វះចន្លោះនៅឡើយកាលពីពេលកន្លងមកនេះ ហើយអនុសញ្ញាឆ្នាំ២០០១
បានបំពេញកង្វះចន្លោះនេះ។

## តាមរបៀបណា?

តាមរយៈមធ្យោបាយនៃការបង្កើតអនុសញ្ញា ដែលត្រូវបានអនុម័តដោយស្ថាប័នអន្តរជាតិដូចជាអង្គការយូណេស្កូជាដើម។ អនុសញ្ញានេះត្រូវអនុវត្តចំពោះបណ្ដាប្រទេសទាំងឡាយណា ដែលផ្ដល់សច្ចាប័នដល់វា មានន័យថាបណ្ដាប្រទេសទាំងនោះចុះហត្ថលេខាលើអនុសញ្ញា និងអនុវត្តអនុសញ្ញានៅក្នុងក្របខណ្ឌច្បាប់នៃប្រទេសរបស់ខ្លួន។

## អ្វីខ្លះ?

អនុសញ្ញាឆ្នាំ២០០១ គូសបញ្ជាក់អំពីគោលការណ៍មូលដ្ឋាននានាសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក។ គោលការណ៍មូលដ្ឋានទាំងនេះរួមមាន៖ កាតព្វកិច្ចត្រូវអភិរក្សបេតិកភណ្ឌវប្បធម៌ក្រោមទឹកនៅនឹងកន្លែងដែលជាជម្រើសទីមួយ ហើយបន្ដមកទៀតគឺថា គ្មានការធ្វើអាជីវកម្មពាណិជ្ជ-កម្មណាមួយលើបេតិកភណ្ឌក្រោមទឹកត្រូវបានអនុញ្ញាតនោះឡើយ។ អនុសញ្ញានេះក៏ផ្ដល់ផងដែរ នូវប្រព័ន្ធសហប្រតិបត្តិការរវាងរដ្ឋសម្រាប់បេតិក-ភណ្ឌលិចក្នុងទឹក និងលិខិតបទដ្ឋានងាយៗទាំងឡាយ ដែលត្រូវបានគេទទួលស្គាល់ សម្រាប់ការស្រាវជ្រាវបុរាណវិទ្យាក្រោមទឹក។

## អ្នកណា?

អនុសញ្ញាត្រូវបានផ្ដល់សច្ចាប័នដោយ៤៧ប្រទេស រួមទាំងកម្ពុជាផងដែរ។



ពិព័រណ៍នេះទទួលបានការគាំទ្រពី៖

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

Flanders
State of the Art

LYCÉE FRANÇAIS RENÉ DESCARTES
PHNOM PENH - ROYAUME DU CAMBODGE

# សង្គ្រាមលោកលើកទី១
## សំណល់ពីសង្គ្រាមនៅបាតសមុទ្រ



photo by Mark Spencer

United Nations
Educational, Scientific and
Cultural Organization

The Protection of
the Underwater Cultural
Heritage

# សង្គ្រាមនៅលើផ្ទៃសមុទ្រ



សង្គ្រាមលោកលើកទី១ បានចាប់ផ្តើមនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩១៤ និងបានបញ្ចប់ទៅវិញនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩១៨។ កងទ័ពប្រមាណជាង៧០ លាននាក់ បានប្រឡូកក្នុងជម្លោះនេះ វាជាជម្លោះដែលបានក្លាយជាសង្គ្រាមមួយក្នុងចំណោមសង្គ្រាមធំៗជាងគេក្នុងប្រវត្តិសាស្រ្ត។ សង្គ្រាមនេះ ពាក់ព័ន្ធជាមួយបណ្តាប្រទេសចំនួន៧០ និងធ្វើឲ្យវាក្លាយជាសង្គ្រាមលោកមួយយ៉ាងពិតប្រាកដ។

លក្ខណៈសំខាន់មួយនៃសង្គ្រាមលោកលើកទី១ គឺការប្រយុទ្ធគ្នាតាមជើងទឹករវាងកងនាវាទ័ពល្បីៗ។ ការប្រយុទ្ធគ្នារវាងនាវាជើងទឹកអាល្លឺម៉ង់និងនាវាមុជទឹករបស់សម្ព័ន្ធមិត្ត គឺជាជំហ៊ានថ្មីមួយទៀត ដែលខុសពីសង្គ្រាមប្រើនាវានៅលើទឹកតាមបែបបុរាណ និង ឆ្ពោះទៅការធ្វើសង្គ្រាមដោយនាវាមុជទឹកតាមបែបទំនើប។ នាវារាប់ពាន់គ្រឿងបានលិចនៅក្នុងការប្រយុទ្ធគ្នា ទាំងនេះ ហើយមនុស្សរាប់លាននាក់បានបាត់បង់ជីវិត។ មនុស្សជាច្រើនផ្សេងទៀតឃ្លានគ្មានអាហារបរិភោគរហូតដល់ស្លាប់ ដោយសារការហ៊ុំព័ទ្ធជាប់គាំងនៅក្នុងសមុទ្រ។ សំណល់ នៃសង្គ្រាមទាំងនេះ នៅមានច្រើនអនេកនៅបាតសមុទ្រ។

ប្រទេសក្រោមអាណានិគម និងក្រោមអាណាព្យាបាល រួមទាំងកម្ពុជាផងដែរ បានចូលរួមយ៉ាងទូលំទូលាយនៅក្នុងសង្គ្រាមលោកលើកទី១ ដោយបញ្ជូនទ័ព កម្លាំងពលកម្ម និងស្បៀងអាហារផ្សេងៗ ទៅបណ្តាប្រទេសមហាអំណាចចក្រពត្តិនៅអឺរ៉ុប។



## ចាញ់នៅសមុទ្រ បង្កកពេលវេលា

នៅតាមឆ្នេរសមុទ្រនានានៅក្នុងពិភពលោក នាវាជាច្រើនបានរងការខូចខាត។ នាវាទាំងនោះ បានជាប់គៀងនៅតាមឆ្នេរសមុទ្រ ហាក់ដូចជាចំណុចភ្ជាប់ទៅអតីតកាល។ ទីតាំងនីមួយៗគឺជាកញ្ចប់ខ្ចប់ពេលវេលានៃអតីតកាល ដែលគេអាចបើកមើលសម្រាប់មនុស្សជំនាន់ក្រោយ និងបើកសោរដោយបុរាណវិទូសមុទ្រ។

ទោះបីជាពួកគេធ្វើការនៅក្នុងបរិស្ថានប្រកបដោយភាពគ្រោះថ្នាក់ជាងលើដីយ៉ាងណាក្តី ក៏បុរាណវិទូក្រោមទឹកនៅតែគោរពតាមគោលការណ៍ដូចគ្នានឹងបុរាណវិទូដែលធ្វើការនៅលើដីដូច្នោះដែរ។ ទីតាំងមួយត្រូវតែធ្វើការស្រាវជ្រាវជាមុនសិន ដើម្បីបង្កើតផែនទីដែលមានការវិភាគយ៉ាងលំអិត ទើបគេអាចចូលទៅពិនិត្យសំណល់តួកប៉ាល់បាន។ ជាញឹកញ៉យ កិច្ចការនេះនឹងផ្តល់ព័ត៌មានគ្រប់គ្រាន់ហើយសម្រាប់ធ្វើការបកស្រាយអំពីអត្ថន័យរបស់វា ដោយមិនចាំបាច់ប៉ះពាល់វាឡើយ។ សំណល់តួកប៉ាល់ជាប្រវត្តិសាស្រ្តនឹងត្រូវបានគេធ្វើកំណាយនៅក្នុងលក្ខខណ្ឌលើកលែងមួយចំនួនប៉ុណ្ណោះ។



# បេតិកភណ្ឌវប្បធម៌ក្រោមទឹក



photo by Mark Spencer

ទោះបីជាមាននាវាជាច្រើនបានចូលរួមនៅក្នុងសង្គ្រាមលោកលើកទី១យ៉ាងណាក្តី ក៏បេតិកភណ្ឌបុរាណវិទ្យាដែលជាសំណល់នៅបាតសមុទ្រនៃសង្គ្រាមលោកលើកទី១ កំពុងប្រឈមនឹងហានិភ័យដែលគេអាចបំភ្លេចចោល ហើយសំណល់ទាំងនោះកំពុងរងសភាពគ្រោះថ្នាក់ ដោយសារគ្មានការការពារ។ លក្ខណៈបែបនេះ គឺបណ្តាលមកពីការយល់ដឹងតិចតួចរបស់សាធារណជនអំពីបេតិកភណ្ឌប្រភេទនេះ នោះក៏ដោយសារទីតាំងរបស់វា គឺនៅបាតសមុទ្រឯណោះ។ លើសពីនេះទៀត ដោយសារភាពល្ងង់ខ្លៅ និងពេលខ្លះ ដោយសារការស្វែងរកផលចំណេញពីបុគ្គលមួយចំនួន បេតិកភណ្ឌនេះត្រូវបានគេធ្វើចំណាត់ការដោយគ្មានការយកចិត្តទុកដាក់។ សំណល់តួកប៉ាល់ត្រូវបានគេប៉ះពាល់និងបំផ្លិចបំផ្លាញ ដោយគ្មានការកត់ត្រា គ្មានការស្រាវជ្រាវ ឬគ្មានការពិគ្រោះយោបល់ជាមួយប្រទេសពាក់ព័ន្ធឡើយ។ ដែកដែលមានសារធាតុចម្លងទាប និងតួកប៉ាល់ដែលគេគិតថាមានតម្លៃ ពិតជាទាក់ទាញជនស្វែងរកទ្រព្យ ជនទាំងនោះបំផ្លាញមិនត្រឹមតែក្នុងបរិបទបុរាណវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញផ្នូរសង្គ្រាមទៀតផង ដោយសារតែដំណើរការរុករកដែកនេះឯង។

បុរាណវិទូក្រោមទឹកត្រូវតែជាអ្នកដំបូងដែលត្រូវពិនិត្យមើលទីតាំងប្រវត្តិសាស្រ្តក្រោមទឹក ដើម្បីវាយតម្លៃទីតាំងទាំងនោះ និងដើម្បីធានាឲ្យមានការសិក្សាស្រាវជ្រាវ និងអភិរក្សឲ្យបានសមស្រប។